ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ ០៤ សរណន.សកបយ

រាជធានីភ្នំពេញ . ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៣

# សារាចរណែនាំអនុវត្ត

## អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២

## ស្តីពីការកែសំរួល ការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សថ្មី

ដើម្បីអនុវត្តតាមមាត្រា២ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការកែសំរួល ការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមធ្វើការណែនាំអំពីរបៀបគិតប្រាក់សោធន ដូចខាងក្រោម :

ក- របៀបគិតប្រាក់សោធនតាមបៀវត្សចាស់ ទៅជាប្រាក់សោធនគិតតាមបៀវត្សមូលដ្ឋាន :

១- ប្រាក់សោធនគិតតាមបៀវត្សមូលដ្ឋាន ខ្ពស់ជាងប្រាក់សោធនគិតតាមបៀវត្សចាស់ :

ឧទាហរណ៍ទី១ : បុគ្គលិកម្នាក់បានចូលនិវត្តន៍ នៅថ្ងៃទី០១ ខែ តុលា ឆ្នាំ ១៩៩០ មុនពេលចូលនិវត្តន៍គាត់មានអតីតភាពការងាររួម ៣៨ ឆ្នាំ ដែលក្នុងនោះមាន១១ឆ្នាំក្នុងរបបរដ្ឋកម្ពុជា និងមានតារាងកាំប្រាក់ ខ III ៦ = ៣៣ ៤០០ ៛០០ គាត់ទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែចំនួន ៤០ ២៨០ ៛៤០ រហូតដល់ថ្ងៃទី០១.០១.០២។ ក្នុងករណីនេះ ការគណនាប្រាក់សោធននិវត្តន៍តាមបៀវត្សមូលដ្ឋាន មានដូចខាងក្រោម :

- តារាងកាំប្រាក់ ខ III ៦ = ៣៣ ៤០០ ៛០០ ត្រូវបានធ្វើសមាហរណកម្មទៅជាបៀវត្សមូលដ្ឋាន គ ៣.៩ = ៥២ ២០០ ៛០០

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ : $\frac{៥២\ ២០០\ ៛០០ \times ៨០}{១០០}$ = ៤១ ៧៦០ ៛០០

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៤១ ៧៦០ ៛០០ ត្រូវតម្លើងអោយស្មើប្រាក់បៀវត្សមូលដ្ឋានអប្បបរមាប្រចាំខែរបស់សាមីជន គ ៣.១៤ = ៤៥ ០០០ ៛០០

- ដូច្នេះប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ = ៤៥ ០០០ ៛០០

ឧទាហរណ៍ទី២ : មន្ត្រីម្នាក់បានចូលនិវត្តន៍នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៨ មុនពេលចូលនិវត្តន៍គាត់មានអតីតភាពការងាររួម ៣៥ ឆ្នាំ និងមានតារាងកាំប្រាក់ ក II ៧.២ = ៤០ ៦០០ រៀល ហើយគាត់ទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែចំនួន ៦៧ ៤២០ រៀល រហូតដល់ថ្ងៃទី ០១.០១.០២ ។ ក្នុងករណីនេះ ការគណនាប្រាក់សោធននិវត្តន៍តាមបៀវត្សមូលដ្ឋាន មានដូចខាងក្រោម :

- តារាងកាំប្រាក់ ក II ៧.២ = ៤០ ៦០០ រៀល ត្រូវបានធ្វើសមាហរណកម្មទៅជាបៀវត្សមូលដ្ឋាន ក ៣.៥ = ១១៩ ៧០០ រៀល ( ៣០០ x ៣៩៩ )

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ : $\frac{១១៩\ ៧០០\ រៀល \times ៨០}{១០០}$ = ៩៥ ៧៦០ រៀល

ឧទាហរណ៍ទី៣ : មន្ត្រីម្នាក់បានចូលនិវត្តន៍នៅថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៨ មុនពេលចូលនិវត្តន៍គាត់មានអតីតភាពការងាររួម ៣៥ ឆ្នាំ និងមានតារាងកាំប្រាក់ គ II ២ = ២៦ ៤០០ រៀល ហើយគាត់ទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែចំនួន ៤២ ៤៨០ រៀល រហូតដល់ថ្ងៃទី ០១.០១.០២ ។ ក្នុងករណីនេះ ការគណនាប្រាក់សោធននិវត្តន៍តាមបៀវត្សមូលដ្ឋាន មានដូចខាងក្រោម :

- តារាងកាំប្រាក់ គ II ២ = ២៦ ៤០០ រៀល ត្រូវបានធ្វើសមាហរណកម្មទៅជាបៀវត្សមូលដ្ឋាន ឃ ១.៥ = ៤៤ ៧០០ រៀល និង មានប្រាក់បង្គ្រប់ ២ ២០០ រៀល

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ : $\frac{៤៤\ ៧០០\ រៀល \times ៨០}{១០០}$ = ៣៥ ៧៦០ រៀល

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៣៥ ៧៦០ រៀល ត្រូវតម្លើងអោយស្មើ ប្រាក់បៀវត្សមូលដ្ឋានអប្បបរមា របស់សាមីជន ឃ ១.៦ = ៤២ ៣០០ រៀល
- បូកបន្ថែមប្រាក់បង្គ្រប់ = ២ ២០០ រៀល
- ដូច្នេះប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ = ៤៤ ៥០០ រៀល

២- ប្រាក់សោធនគិតតាមបៀវត្សមូលដ្ឋាន ទាបជាងប្រាក់សោធនគិតតាមបៀវត្សចាស់ :

ឧទាហរណ៍ : មន្ត្រីម្នាក់បានចូលនិវត្តន៍នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០១ មុនពេលចូលនិវត្តន៍គាត់មានអតីតភាពការងាររួម ៣៣ ឆ្នាំ និងមានតារាងកាំប្រាក់ គ I ៣ = ៣១ ៤០០ រៀល ហើយគាត់ទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែចំនួន ៤៨ ៣៨០ រៀល រហូតដល់ថ្ងៃទី ០១.០១.០២ ។ ក្នុងករណីនេះ ការគណនាប្រាក់សោធននិវត្តន៍តាមបៀវត្សមូលដ្ឋាន មានដូចខាងក្រោម :

- តារាងកាំប្រាក់ គ I ៣ = ៣១ ៤០០ រៀល ត្រូវបានធ្វើសមាហរណកម្មទៅជាបៀវត្សមូលដ្ឋាន គ ៣.១០ = ៥០ ៤០០ រៀល

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ : $\frac{៥០\ ៤០០\ រ០០ \times ៨០}{១០០}$ = ៤០ ៣២០ រ០០

- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ ៤០ ៣២០ រ០០ ត្រូវតម្លើងអោយស្មើ ប្រាក់បៀវត្សមូលដ្ឋានអប្បបរមារបស់សាមីជន គ :៣.១៤. = ៤៥ ០០០ រ០០
- ប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែគិតតាមបៀវត្សមូលដ្ឋាននេះ ទាបជាង ប្រាក់សោធននិវត្តន៍គិតតាមបៀវត្សចាស់ ។ ក្នុងករណីនេះ ត្រូវតម្លើងឱ្យស្មើ ប្រាក់សោធននិវត្តន៍គិតតាមបៀវត្សចាស់វិញ = ៤៨ ៣៨០ រ០០
- ដូច្នេះប្រាក់សោធននិវត្តន៍សុទ្ធសាធប្រចាំខែ = ៤៨ ៣៨០ រ០០

\+ កំណត់សំគាល់ ៖ ការគណនាប្រាក់សោធននិវត្តន៍តាមបៀវត្សមូលដ្ឋាន បើមានករណីទាបជាងប្រាក់សោធននិវត្តន៍គិតតាមបៀវត្សចាស់ ត្រូវតម្លើងឱ្យស្មើដូចករណីខាងលើនេះដែរ ។

៣- ការគណនាប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ មានរបៀបគិតដូចប្រាក់សោធននិវត្តន៍ដែរ ប៉ុន្តែមិនត្រូវទាបជាង ៥០ ភាគរយ នៃបៀវត្សមូលដ្ឋានអប្បបរមារបស់សាមីជនឡើយ ។

៤- ការគណនារយៈពេលបំពេញការងារ ៥ ឆ្នាំក្នុងរបបរដ្ឋកម្ពុជា ត្រូវបានអនុវត្តដូចរយៈពេលបំពេញការងារ ២០ ឆ្នាំ ដែលមានចែងក្នុងអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល ។

**ខ. ភារកិច្ចរបស់ក្រសួង ស្ថាប័ន :**

សំណុំលិខិតចូលនិវត្តន៍ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ របស់ក្រសួង ស្ថាប័ននីមួយៗ ត្រូវអនុវត្តតាមមាត្រាទី៦ នៃអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលអោយចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធពតិមានវិទ្យា និងអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្តីពីការកែសំរួលការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល តាមប្រព័ន្ធបៀវត្សមូលដ្ឋាន ។

**គ. ភារកិច្ចរបស់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត ក្រុង :**

មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវធ្វើលិខិតស្នើសុំប្តូរប្រាក់សោធនប្រចាំខែរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ មកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយភ្ជាប់មកជាមួយនូវ :

- សៀវភៅនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ

- តារាងបើកប្រាក់សោធនប្រចាំខែចុងក្រោយ ចំនួន ០១ ច្បាប់
- តារាងគណនាប្រាក់សោធននិវត្តតាមបៀវត្សមូលដ្ឋាន និងប្រាក់សោធននិវត្តតាមបៀវត្សចាស់ ដូចមានគំរូជូនភ្ជាប់ ចំនួន ០១ ច្បាប់

សារាចរណែនាំនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត ក្រុង

"ដើម្បីសហការអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

រដ្ឋមន្ត្រី

អ៊ិត សំហេង